# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣០/១៨ - ខេន ស្តុត ស៊ូ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **តាំង ទ្រី**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ខេន ស្តុត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៧៨ ៧៧៧ ៦១៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក សុះ ម៉ើ | ប្រធានរដ្ឋបាល |
| ២- លោក ឡាច សារុន | ទីប្រឹក្សា |
| ៣- លោក អ៊ុក អ៊ុន | រដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខេន ស្តុត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៩៧ ៨៨៤ ៥៦៨៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោកស្រី សៀន សុខល្បៀប | ប្រធានសហជីព |
| ២- លោក អន សុខរី | លេខាធិការសហជីព |

៣- លោកស្រី អ៊ុក ជាលីម		អនុប្រធានសហជីព

៤- កញ្ញា អ៊ុំ ឌីណា		អគ្គលេខាធិការសម្ព័ន្ធសហជីពសេរីស្ត្រីកាត់ដេរ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែស្នើសុំឱ្យក្រុមហ៊ុនទទួលយកសំបុត្រពេទ្យដូចពីមុនវិញ។

២- កម្មករនិយោជិតនៅតែស្នើឱ្យក្រុមហ៊ុនអនុវត្តមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ។

៣- កម្មករនិយោជិតនៅតែស្នើឱ្យក្រុមហ៊ុន នៅពេលកម្មការិនីមានផ្ទៃពោះ សូមកុំឱ្យគាត់ដាក់ច្បាប់សម្រាលមុនខែដែលគាត់ត្រូវសម្រាល (អនុវត្តដូចមុន)។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១០៩៧ កប/កឆ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨។

### សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៩៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃព្រហស្បតិ៍ ៥កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីករណីកម្មករនិយោជិតទាមទារឱ្យនិយោជកកែលម្អលក្ខខណ្ឌការងារ ចំនួន ៨ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ៨ ចំណុច នៅថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១៨ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា ចំនួន ៣ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ទាំង ៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១០៩៧ កប/កឆ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ៣ ចំណុច នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ៣ ចំណុចនេះ បន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំណុចវិវាទ ចំនួន ៣ នេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ទៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិចុះលេខ ០១០/១៨ ខសស ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ ស្តេឡា ជានាយកសហគ្រាស យីហោ ខេន ស្ព័ត ស៊ូ ខូអិលធីឌី គោរពជូន លោកប្រធានលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក សុះ មើ លោក ឡាច សារុន និងលោក អ៊ុក អ៊ុន។

២- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម ខេន ស្ព័ត ស៊ូ លេខ ៦៨២៣ ឧសកឧ.វប.១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៣- ប័ណ្ណពន្ធប៉ាតង់ឆ្នាំ២០១៨ សហគ្រាស ខេន ស្ព័ត ស៊ូ លេខ PTL ២០១៨០១២៨៨៦ អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨។

៤- ប្រកាសបង្កើតរោងចក្រ ខេន ស្ព័ត ស៊ូ លេខ ៦២៥ ឧសកឧ.ប្រក.១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ លេខ ៥១១ ប.ក/កឆ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង។

៦- លិខិតស្នើសុំរបស់តំណាងសហជីពសេរីស្ត្រីកាត់ដេរប្រចាំក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គោរពជូនមក លោកប្រធានមន្ទីរ ខេត្តកំពង់ឆ្នាំង ជួយដោះស្រាយលក្ខខណ្ឌការងារ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨។

៨- អនុសញ្ញារួមនៃការងារ រវាងសហជីពកម្មករកម្ពុជារោងចក្រ ខេន ស្ព័ត ស៊ូ ខូអិលធីឌី និងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ខូអិលធីឌី អាណត្តិទី១ បានចុះបញ្ជីលេខ ៤៦ កប/កឆ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ៩៤៨ កប/កឆ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បញ្ជាក់ថា សហជីពសេរីស្ត្រីកាត់ដេរ នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ជាអង្គការវិជ្ជាជីវៈមួយ ត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

២- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពសេរីស្ត្រីកាត់ដេរនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ៩៤៦ កប/កឆ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១០៩៧ កប/កឆ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០១៨។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០០៦/១៨ កប/កឆ/លបវ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង។

THE ARBITRATION COUNCIL

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២០៦ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១៣រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២០៧ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១៣រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ខូ អិលធីឌី គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការផលិតស្បែកជើង និងបានទទួលវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម (ឆ្នាំទី៧) ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។
- ភាគីនិយោជកបានបញ្ជាក់ថា បច្ចុប្បន្នក្រុមហ៊ុននេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ៧២៥០ នាក់។
- សហជីពសេរីស្ត្រីកាត់ដេរនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ បានទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាសហជីពក្រោមលេខ ៩៤៦ កប/កឆ និងមានលិខិតទទួលស្គាល់តាមរយៈលិខិតលេខ ៩៤៨ កប/កឆ ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ ដោយក្នុងនោះ រួមមាន៖ ១. លោកស្រី សៀន សុខលាប ជាប្រធាន ២. លោកស្រី អ៊ុក ដាលីម ជាអនុប្រធាន និង៣. លោក អន សុខវី ជាលេខាធិការ។
- នៅក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៦/១៨ កប/កឆ/លបវ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. លោកស្រី សៀន សុខលៀប ២. លោកស្រី អ៊ុក ដាលីម និង៣. លោក អន សុខវី ជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការ គឺមានវត្តមានរបស់តំណាងកម្មករនិយោជិតទាំង ៣ នាក់។
- ភាគីនិយោជកបានលើកឡើងថា សហជីពសេរីស្ត្រីកាត់ដេរ មិនមានសិទ្ធិតំណាងឱ្យកម្មករនិយោជិតដែលមិនមែនសមាជិករបស់គាត់ទេ ហើយសហជីពនេះ ក៏មិនទាន់មានភាពជាតំណាងបំផុតដែរ។

- នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរបានទទួលស្គាល់ថា នៅក្នុងក្រុមហ៊ុនមិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតនៅតែស្នើសុំឱ្យនិយោជកទទួលយកសំបុត្រពេទ្យដូចមុនវិញ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧ នៅពេលកម្មករនិយោជិតឈឺ ហើយមានលិខិតបញ្ជាក់ពីពេទ្យ (លិខិតស្នាមនានាពីពេទ្យ) និយោជកអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកចំនួន ១ ថ្ងៃ ដោយរក្សាប្រាក់ឈ្នួល និង ប្រាក់រង្វាន់ធ្វើការទៀងទាត់នៅដដែល។ ដោយឡែក នៅឆ្នាំ២០១៨ និយោជកមិនទទួលយកវេជ្ជបញ្ជាពីគ្រូពេទ្យទេ លើកលែងតែសំបុត្រពេទ្យដែលមានបញ្ជាក់អំពីចំនួនថ្ងៃដែលកម្មករនិយោជិតត្រូវឈប់សម្រាក ទើបនិយោជកទទួលយក និងអនុញ្ញាតច្បាប់ឱ្យឈប់សម្រាក ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅដដែល។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកទទួលយកសំបុត្រពេទ្យ ឬវេជ្ជបញ្ជាពីពេទ្យនៅពេលកម្មករនិយោជិតឈឺ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា នៅពេលកម្មករនិយោជិតឈឺតិចតួច ដូចជា ចុកពោះ ឬរាគ ជាដើម ហើយទៅជួបគ្រូពេទ្យ គឺគ្រូពេទ្យមិនចេញសំបុត្រពេទ្យឱ្យទេ គឺគ្រាន់តែចេញវេជ្ជបញ្ជាឱ្យទិញថ្នាំនិងមិនតម្រូវឱ្យសម្រាកនៅពេទ្យទេ។
- ភាគីនិយោជកបានបញ្ជាក់ថា ការអនុញ្ញាតច្បាប់ឈឺ គឺផ្អែកទៅលើសំបុត្របញ្ជាក់ពីគ្រូពេទ្យដែលមានឈ្មោះ ហត្ថលេខា និងត្រារបស់មន្ទីរពេទ្យដែលសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។ ក្នុងករណីដែលនិយោជកទទួលយកសំបុត្រពេទ្យនោះ និយោជករក្សាប្រាក់ឈ្នួលនិងប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យកម្មករនិយោជិតនៅថ្ងៃដែលគាត់ឈប់សម្រាកឈឺនោះ។
- ភាគីនិយោជកបានបន្តថា ក្នុងករណីដែលកម្មករនិយោជិតមានវេជ្ជបញ្ជាពីគ្រូពេទ្យខាងក្រៅ ពួកគាត់អាចយកវេជ្ជបញ្ជានោះមកឱ្យពេទ្យប្រចាំនៅក្រុមហ៊ុនពិនិត្យមើលថា តើជំងឺរបស់កម្មករនិយោជិតត្រូវឈប់សម្រាកចំនួន ១ ថ្ងៃ ដែរ ឬទេ? ក្នុងករណីដែលកម្មករនិយោជិតគ្រាន់តែទៅពេទ្យ ដើម្បីបើកថ្នាំ គឺមិនគួរចំណាយពេលយូរទេ រហូតនិយោជកត្រូវផ្តល់ជូនច្បាប់ឈប់សម្រាកចំនួន ១ ថ្ងៃ នោះទេ។ ភាគីកម្មករនិយោជិតបានឆ្លើយតបថា គ្រូពេទ្យប្រចាំនៅក្នុងក្រុមហ៊ុនមិនមានឧបករណ៍គ្រប់គ្រាន់ សម្រាប់ពិនិត្យកម្មករនិយោជិតទេ។
- ភាគីនិយោជកបញ្ជាក់ថា និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតទេ។
- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលទទួលបានទិដ្ឋាការពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ត្រង់ចំណុច ៤.២.២.៦ ចែងថា៖ *"រោងចក្រទទួលស្គាល់តែលិខិតបញ្ជាក់ ដែលចេញដោយគ្រូពេទ្យនៃមន្ទីរពេទ្យស្របច្បាប់ (បានចុះបញ្ជី) ដោយមានឈ្មោះ ហត្ថលេខារបស់គ្រូពេទ្យតែប៉ុណ្ណោះ។"*

THE ARBITRATION COUNCIL

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតនៅតែស្នើសុំឱ្យនិយោជកអនុវត្តតាមមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតដែលសម្រាលកូនរួច ចេញពីធ្វើការមុនម៉ោងដើម្បីបំបៅកូន ចំនួន ១ ម៉ោង ពីម៉ោង ៣ ៖ ០០ ដល់ ៤ ៖ ០០ រសៀល (ចុងម៉ោងការងារ) ។
- ភាគីទាំងពីរបានទទួលស្គាល់ថា និយោជកមានបន្ទប់សម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រីយកកូនមកបំបៅនៅក្នុងក្រុមហ៊ុន។ និយោជកអនុញ្ញាតកម្មករនិយោជិតជាស្ត្រីឱ្យបំបៅកូនរយៈពេល សរុប ១ម៉ោង ក្នុងមួយថ្ងៃ ក្នុងម៉ោងការងារ គឺកន្លះម៉ោងនៅពេលព្រឹក និងកន្លះម៉ោងនៅពេលរសៀល នៅក្នុងក្រុមហ៊ុន។ ដោយឡែក និយោជកមិនអនុញ្ញាតពេល ១ ម៉ោងនេះ សម្រាប់កម្មករនិយោជិតជាស្ត្រីណា ដែលមិនយកកូនមកបំបៅនៅក្នុងក្រុមហ៊ុនទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតជាស្ត្រីដែលមានកូនតូចត្រូវបំបៅមិនអាចយកកូនមកបំបៅនៅក្នុងក្រុមហ៊ុនបានទេ ដោយសារពួកគាត់សុទ្ធតែជិះឡានឈ្នួលជាក្រុមមកធ្វើការ។ ហេតុនេះ វាមិនមានភាពងាយស្រួលសម្រាប់យកកូនតូចមកជាមួយតាមឡានទេ។
- ភាគីកម្មករនិយោជិតធ្វើការទាមទារដោយផ្អែកតាមមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចផ្តល់ជូនតាមការទាមទារបានទេ ដោយសារនិយោជកត្រូវការជួបពិភាក្សាជាមួយសហជីពផ្សេងៗទៀតនៅក្នុងក្រុមហ៊ុន ដើម្បីកំណត់ម៉ោងពេលដ៏ល្អសម្រាប់និយោជក និងកម្មករនិយោជិតជាស្ត្រីដែលមានកូនត្រូវបំបៅ។
- ភាគីនិយោជកបានបន្តថា ម៉ោងធ្វើការនៅក្នុងក្រុមហ៊ុន គឺចែកចេញជាពីរវេន គឺ៖
    - វេនទី ១ ៖ ពេលព្រឹក ចាប់ពីម៉ោង ៧ ៖ ០០ ដល់ម៉ោង ១១ ៖ ០០ និងពេលរសៀល ចាប់ពីម៉ោង ១២ ៖ ០០ ដល់ម៉ោង ១៦ ៖ ០០
    - វេនទី ២ ៖ ពេលព្រឹក ចាប់ពីម៉ោង ៧ ៖ ០០ ដល់ម៉ោង ១១ ៖ ៣០ និងពេលរសៀល ចាប់ពីម៉ោង ១២ ៖ ៣០ ដល់ម៉ោង ១៦ ៖ ០០។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតនៅតែស្នើសុំឱ្យនិយោជកនៅពេលកម្មការិនីមានផ្ទៃពោះ សូមកុំឱ្យគាត់ដាក់ច្បាប់សំរាលមុនខែដែលគាត់ត្រូវសំរាល (អនុវត្តដូចមុន)**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពទៅតាមការស្នើសុំជាក់ស្តែងរបស់កម្មករនិយោជិតម្នាក់ៗ។
- ភាគីទាំងពីរទទួលស្គាល់ថា និយោជកតម្រូវឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាព ចំនួន ១ ខែ មុនពេលសម្រាលកូន។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ជាក់ស្តែងកម្មករនិយោជិតចំនួន ២ នាក់ ដែលមានវត្តមាននៅក្នុងសវនាការ គឺកម្មករនិយោជិត សៀន សុខល្បៀប និងអ៊ុក ដាលីម បានសម្រាលកូនរួចជាង ១ ខែ ហើយត្រូវត្រលប់ចូលធ្វើការវិញ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា៖
    - ០ កម្មករនិយោជិតដែលសម្រាលរួចនៅសរសៃខ្ចី ដូចនេះ ពួកគាត់ត្រូវការពេលវេលាគ្រប់គ្រាន់សម្រាប់សម្រាក ។
    - ០ មានការលំបាកក្នុងការសុំច្បាប់ឈប់សម្រាកបន្តក្រោយពេលត្រលប់ចូលធ្វើការវិញ ។
- ភាគីនិយោជកបានបញ្ជាក់ថា ការតម្រូវឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាព ចំនួន ១ ខែ មុនពេលសម្រាលនេះ ទើបតែចាប់ផ្ដើមអនុវត្តទេ ដោយសារធ្លាប់មានករណីដែលកម្មករនិយោជិតមានផ្ទៃពោះសម្រាលកូននៅក្នុងក្រុមហ៊ុន ។ ហេតុនេះ ការដែលកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពជិតពេលសម្រាលកូនអាចនាំឱ្យមានហានិភ័យ ។
- ភាគីនិយោជកបានបន្តថា និយោជកមិនអាចផ្ដល់ជូនតាមការទាមទារបានទេ ដោយសារច្បាប់មិនបានកំណត់ថា រយៈពេលប៉ុន្មានកម្មករនិយោជិតមានផ្ទៃពោះត្រូវឈប់សម្រាកលំហែមាតុភាពទេ ។ និយោជកនឹងពិភាក្សាឡើងវិញ បើសិនជាមានការលើកឡើងពីសហជីពផ្សេងៗ និងប្រតិភូបុគ្គលិកនៅក្នុងក្រុមហ៊ុន ថារយៈពេលដែលនិយោជកតម្រូវឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាព ចំនួន ១ ខែ មុនពេលសម្រាលកូននេះ ជារយៈពេលយូរពេក ។
- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលទទួលបានទិដ្ឋាការពីមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ត្រង់ចំណុច ១.១០.៥.២ បញ្ជាក់ថា៖ *"លិខិតសុំច្បាប់របស់អ្នកស្នើសុំឈប់សម្រាកសម្រាលកូន ត្រូវភ្ជាប់នូវលិខិតពិនិត្យសម្រាកព្យាបាលដែលមានបោះត្រារបស់មន្ទីរពេទ្យស្របច្បាប់ និងប័ណ្ណសម្គាល់ស្ត្រីមានផ្ទៃពោះហើយត្រូវប្រគល់ឱ្យផ្នែករដ្ឋបាល ដើម្បីបញ្ជូនទៅផ្នែកទូទាត់ប្រាក់បៀវត្សរ៍ និងវត្តមានឱ្យបាន ១៥ ថ្ងៃ មុនពេលឈប់សម្រាក ។"*

**ហេតុផលនៃសេចក្ដីសម្រេច ÷**

មុននឹងពិចារណាលើចំណុចទាមទារខាងក្រោមនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាអំពីដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន ។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្ដាច់មុខ ។"* ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្ដាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន ។ សិទ្ធិផ្ដាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ ។

*(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី)*

នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរបញ្ជាក់ថា នៅក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ មិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតនោះទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"* ។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចារ សម្រាប់ដោះស្រាយវិវាទការងាររួម។"* ។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិតឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិត ដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិតដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៧/១៦-យូនីកគា ថេកណេឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និង លេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

ក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៦/១៨ កប/គឆ/ធម្មវិវាទ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. លោកស្រី សៀន សុខលៀប ២. លោកស្រី អ៊ុក ដាលីម និង៣. លោក អន សុខវី ជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងការដោះស្រាយវិវាទ

ការងាររួម។ នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺតំណាងកម្មករនិយោជិតទាំង ៣ នាក់ មានវត្តមានចូលរួមសវនាការ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៣ នាក់ មានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទនៅក្នុងសំណុំរឿងនេះ សម្រាប់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ដែលជាដើមបណ្តឹង។

**ចំណុចវិវាទទី ១ ៖ *ភាគីកម្មករនិយោជិតនៅតែស្នើសុំឱ្យនិយោជកទទួលយកសំបុត្រពេទ្យ ឬវេជ្ជបញ្ជាពីពេទ្យនៅពេលកម្មករនិយោជិតឈឺ***

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចទទួលយកសំបុត្រពេទ្យ ឬវេជ្ជបញ្ជាពីពេទ្យឈឺ ដែរ ឬទេ?

ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧ នៅពេលកម្មករនិយោជិតឈឺ ហើយមានលិខិតបញ្ជាក់ពីគ្រូពេទ្យណាក៏ដោយ និយោជកអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកចំនួន ១ ថ្ងៃ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅដដែល។ ដោយឡែក នៅឆ្នាំ២០១៨ និយោជកមិនទទួលយកវេជ្ជបញ្ជាពីគ្រូពេទ្យឡើយ លើកលែងតែសំបុត្រពេទ្យដែលមានបញ្ជាក់ពីចំនួនថ្ងៃដែលកម្មករនិយោជិតត្រូវឈប់សម្រាក ទើបនិយោជកទទួលយក និងអនុញ្ញាតច្បាប់ឱ្យឈប់សម្រាក ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅដដែល។

ភាគីនិយោជកបានបញ្ជាក់ថា ការអនុញ្ញាតច្បាប់ឈឺ គឺផ្អែកទៅលើសំបុត្របញ្ជាក់ពីពេទ្យដែលមានឈ្មោះ ហត្ថលេខា និងត្រាបញ្ជាក់ពីមន្ទីរពេទ្យដែលសហការជាមួយនឹងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។ ក្នុងករណីដែលនិយោជកទទួលយកសំបុត្រពេទ្យនោះ និយោជករក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យកម្មករនិយោជិតនៅថ្ងៃដែលគាត់ឈប់សម្រាកឈឺនោះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការតម្រូវបែបហ្នឹងរបស់និយោជកអាចកំហិតនិយោជិតពីការជ្រើសរើសសេវាព្យាបាលសុខភាពទូលំទូលាយ ដោយសារតែនិយោជកតម្រូវសំបុត្របញ្ជាក់ពីពេទ្យដែលមានឈ្មោះ ហត្ថលេខា និងត្រាបញ្ជាក់ពីមន្ទីរពេទ្យដែលសហការជាមួយនឹងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ឬហត្ថលេខា និងត្រាបញ្ជាក់ពីមន្ទីរពេទ្យ បើសិនដូច្នោះទេកម្មករនិយោជិតអាចរងនូវការកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់។ ផ្ទុយទៅវិញមិនមានបញ្ញត្តិនៃច្បាប់ស្តីពីការងារចែងដូចគោលការណ៍អនុវត្តរបស់និយោជនបែបហ្នឹងនោះឡើយ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រង់ចំណុច ៤.២.២.៦ ចែងថា៖ *"រោងចក្រទទួលស្គាល់តែលិខិតបញ្ជាក់ដែលចេញដោយគ្រូពេទ្យនៃមន្ទីរពេទ្យស្របច្បាប់ (បានចុះបញ្ជី) ដោយមានឈ្មោះ ឬហត្ថលេខារបស់គ្រូពេទ្យតែប៉ុណ្ណោះ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុច ៤.២.២.៦ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន បានបញ្ជាក់ថា និយោជកត្រូវតែទទួលស្គាល់លិខិតបញ្ជាក់ដែលចេញដោយគ្រូពេទ្យនៃមន្ទីរពេទ្យស្របច្បាប់ ដែលបានចុះបញ្ជី ដោយ

THE ARBITRATION COUNCIL

មានឈ្មោះ ឬហត្ថលេខារបស់គ្រូពេទ្យ។ ខ្លឹមសារក្នុងចំណុចនេះ មិនតម្រូវថា ទាល់តែលិខិតបញ្ជាក់ដែលចេញដោយមន្ទីរពេទ្យដែលសហការជាមួយ ប.ស.ស ទើបនិយោជកត្រូវទទួលស្គាល់នោះឡើយ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជកទាក់ទងនឹងការទទួលយកលិខិតបញ្ជាក់ដែលចេញគ្រូពេទ្យដូចរៀបរាប់ខាងលើនេះ គឺមិនមានហេតុផលត្រឹមត្រូវ និង ខុសពីខ្លឹមសារដូចចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនខ្លួន ត្រង់ចំណុច ៤.២.២.៦។ និយោជកមានកាតព្វកិច្ចអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនរបស់ខ្លួន និងបញ្ឈប់ការអនុវត្តរបស់ខ្លួនខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកអនុវត្តតាមចំណុច ៤.២.២.៦ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ដោយត្រូវទទួលស្គាល់រាល់លិខិតបញ្ជាក់ដែលចេញដោយគ្រូពេទ្យ *នៃមន្ទីរពេទ្យស្របច្បាប់ (បានចុះបញ្ជី) ដោយមានឈ្មោះ ឬហត្ថលេខារបស់គ្រូពេទ្យ* ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលសម្រាលកូនរួចចេញពីធ្វើការមុនម៉ោងដើម្បីបំបៅកូន ចំនួន ១ ម៉ោង ពីម៉ោង ៣ ៖ ០០ ដល់ ៤ ៖ ០០ រសៀល (ចុងម៉ោងការងារ)**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថាតើ និយោជកមានកាតព្វកិច្ចអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលសម្រាលកូនរួចចេញពីធ្វើការមុនម៉ោងទៅបំបៅកូន ចំនួន ១ ម៉ោង ពីម៉ោង ៣ ៖ ០០ ដល់ ៤ ៖ ០០ រសៀល (ចុងម៉ោងការងារ) ដែរឬទេ?

មាត្រា១៨៤ នៃច្បាប់ស្តីពីការងារចែងថា ៖ *"ក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃដែលសំរាលកូនរួច ស្ត្រីដែលឱ្យកូនបៅដោះអាចបានពេលមួយម៉ោងក្នុងមួយថ្ងៃដើម្បីបំបៅកូនខ្លួនក្នុងពេលម៉ោងធ្វើការ។ រយៈពេលមួយម៉ោងនេះអាចចែកជាពីរវគ្គដែលមានសាមសិបនាទីក្នុងមួយវគ្គ គឺពេលធ្វើការព្រឹកម្តង និងពេលធ្វើការរសៀលម្តង នៅម៉ោងណាមួយដែលស្ត្រីនោះព្រមព្រៀងជាមួយនិយោជក។ បើគ្មានការព្រមព្រៀងទេ ត្រូវយកម៉ោងនៅពាក់កណ្តាលពេលនៃរយៈពេលនៃម៉ោងធ្វើការនិមួយៗ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងទីតាំងរោងចក្រមានទារកដ្ឋានដែរ មានតែបន្ទប់ទទេរ តែមិនមានអ្នកមើលថែក្មេង ឬសម្ភារៈទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតជាស្ត្រីដែលមានកូនតូចត្រូវបំបៅមិនអាចយកកូនតាមមកបំបៅនៅក្នុងក្រុមហ៊ុនបានទេ ដោយសារពួកគាត់សុទ្ធតែជិះឡានឈ្នួលជាក្រុមពីផ្ទះមកធ្វើការ។ ហេតុនេះ វាមិនអាចមានភាពងាយស្រួលសម្រាប់យកកូនតូចមកជាមួយតាមឡានទេ។ ដោយសារជួបប្រទះលក្ខខណ្ឌលំបាកបែបនេះ កម្មករនិយោជិតជាស្ត្រីគួរតែមានសិទ្ធិសម្រេចថា គួរតែធ្វើការបំបៅកូននៅទៅកន្លែងណា ម៉្យាងទៀត មិនមានបញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវថាត្រូវបំបៅកូននៅទីណានោះទេ។

ចំពោះមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសម្រាលកូនរួច កម្មករនិយោជិតជាស្ត្រីដែលឱ្យកូនបៅដោះ អាចមានពេលចំនួន ១ ម៉ោងក្នុងមួយថ្ងៃ ក្នុងម៉ោងការងារដើម្បីបំបៅកូន។ មាត្រានេះ មិនបានកំណត់ថា ទាល់តែកម្មករនិយោជិតជាស្ត្រីដែល

THE ARBITRATION COUNCIL

ត្រូវយកកូនមកបំបៅនៅក្រុមហ៊ុន ទើបមានសិទ្ធិទទួលបានពេលចំនួន ១ ម៉ោង ដើម្បីបំបៅកូននៅក្នុងម៉ោងការងារទេ។ លើសពីនេះទៀត ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងនិយោជក និងកម្មករនិយោជិត ត្រូវយកម៉ោងនៅពាក់កណ្តាលពេលនៃរយៈពេលនៃម៉ោងធ្វើការនិមួយៗ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅក្នុងករណីនេះ និយោជក និងកម្មករនិយោជិតមិនមានការព្រមព្រៀងគ្នាទាក់ទងនឹងពេលវេលាចំនួន ១ ម៉ោង សម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រីបំបៅកូនក្នុងម៉ោងការងារ។

ចំពោះកម្មករនិយោជិតជាស្ត្រីណាដែលយកកូនមកបំបៅ និយោជកអនុញ្ញាតឱ្យពេលចំនួន ១ ម៉ោង ក្នុងម៉ោងការងារ គឺកន្លះម៉ោងនៅពេលព្រឹក និងកន្លះម៉ោងនៅពេលរសៀលសម្រាប់បំបៅកូន។ នៅក្នុងករណីនេះ និយោជក និងកម្មករនិយោជិតមិនមានការព្រមព្រៀងគ្នាទាក់ទងនឹងពេលវេលាចំនួន ១ ម៉ោង សម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រីបំបៅកូនក្នុងម៉ោងការងារទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជក ទាក់ទងនឹងការអនុញ្ញាតឱ្យពេលចំនួន ១ ម៉ោង ក្នុងម៉ោងការងារ ដល់កម្មករនិយោជិតជាស្ត្រីដែលយកកូនមកបំបៅនៅក្នុងក្រុមហ៊ុន គឺស្របតាមមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលសម្រាលកូនរួចចេញពីធ្វើការមុនម៉ោងទៅបំបៅកូន ចំនួន ១ ម៉ោង ពីម៉ោង ៣ ៖ ០០ ដល់ ៤ ៖ ០០ រសៀល មិនមានមូលដ្ឋានគាំទ្រដោយច្បាប់ទេ។

ដោយឡែក យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សម្រាប់កម្មករនិយោជិតជាស្ត្រីណាដែលមិនយកកូនមកបំបៅនៅក្នុងក្រុមហ៊ុន និយោជកមិនអនុញ្ញាតពេលចំនួន ១ ម៉ោងនេះទេ។ នៅក្នុងករណីនេះ និយោជកត្រូវអនុញ្ញាតពេលចំនួន ១ ម៉ោង ក្នុងម៉ោងការងារ សម្រាប់កម្មករនិយោជិតជាស្ត្រីដែលត្រូវបំបៅកូនឱ្យស្របទៅតាមមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ មិនថាកម្មករនិយោជិតជាស្ត្រីយកកូនមកបំបៅនៅក្នុងក្រុមហ៊ុន ឬចេញទៅបំបៅនៅខាងក្រៅ ពីព្រោះវាជាសិទ្ធិដែលកម្មករនិយោជិតជាស្ត្រីត្រូវទទួលបានតាមផ្លូវច្បាប់។

ជាសរុប ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលសម្រាលកូនរួចនូវពេលចំនួន ១ ម៉ោង នៅចុងម៉ោងការងារ (ម៉ោង ៣ ៖ ០០ ដល់ ៤ ៖ ០០ រសៀល) ដើម្បីបំបៅកូន។
- បង្គាប់ឱ្យនិយោជកអនុញ្ញាតពេលចំនួន ១ ម៉ោង ក្នុងម៉ោងការងារ សម្រាប់កម្មករនិយោជិតជាស្ត្រីដែលបំបៅកូនឱ្យស្របតាមមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតមានថ្ងៃពោះឈប់សម្រាកលំហែមាតុភាពទៅតាមការស្នើសុំជាក់ស្តែងរបស់កម្មករនិយោជិតម្នាក់ៗ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថាតើ និយោជកមានកាតព្វកិច្ចអនុញ្ញាតឱ្យកម្មករនិយោជិតម្នាក់ៗ ផ្ទៃពោះឈប់សម្រាកលំហែមាតុភាពទៅតាមការស្នើសុំជាក់ស្តែងរបស់កម្មករនិយោជិតម្នាក់ៗដែរឬទេ?

ARBITRATION COUNCIL

មាត្រា ១៨២ នៃច្បាប់ស្តីពីការងារចែងថា៖ *"ក្នុងសហគ្រាសទាំងអស់ដែលមានរាប់ក្នុងមាត្រា ១ នៃច្បាប់នេះ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សំរាកកៅសិបថ្ងៃដើម្បីសំរាលកូន ។"*

នៅក្នុងមាត្រា ១៨២ នៃច្បាប់ស្តីពីការងារខាងលើ បានកំណត់ថា កម្មករនិយោជិតជាស្ត្រីមានសិទ្ធិឈប់សម្រាកចំនួន ៩០ ថ្ងៃដើម្បីសម្រាលកូន ប៉ុន្តែមាត្រានេះមិនបានកំណត់ថា កម្មករនិយោជិតជាស្ត្រីត្រូវសុំច្បាប់ឈប់សម្រាកលំហែមាតុភាពនៅពេលណានោះទេ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រង់ចំណុច ១.១០.៥.២ បញ្ជាក់ថា៖ *"លិខិតសុំច្បាប់របស់អ្នកស្នើសុំឈប់សម្រាកសម្រាលកូន ត្រូវភ្ជាប់នូវលិខិតពិនិត្យសម្រាកព្យាបាលដែលមានបោះត្រារបស់មន្ទីរពេទ្យស្របច្បាប់ និងប័ណ្ណសម្គាល់ស្ត្រីមានផ្ទៃពោះហើយត្រូវប្រគល់ឱ្យជំនួយការរដ្ឋបាល ដើម្បីបញ្ជូនទៅផ្នែកទូទាត់ប្រាក់បៀវត្សរ៍ និងវត្តមានឱ្យបាន ១៥ ថ្ងៃ មុនពេលឈប់សម្រាក ។"*

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រង់ចំណុច ១.១០.៥.២ បានបញ្ជាក់ពីរយៈពេលចំនួន ១៥ ថ្ងៃ មុនពេលឈប់សម្រាក ដែលអ្នកស្នើសុំច្បាប់ឈប់សម្រាកសម្រាលកូន ត្រូវប្រគល់លិខិតសុំច្បាប់ឱ្យខាងផ្នែករដ្ឋបាល ប៉ុន្តែចំណុចនេះ មិនបានបញ្ជាក់ថា កម្មករនិយោជិតមានផ្ទៃពោះត្រូវឈប់សម្រាកពេលណា មុនពេលសម្រាលកូននោះទេ។

នៅក្នុងករណីនេះ ជាការអនុវត្តជាក់ស្តែង និយោជកបានតម្រូវឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពចំនួន ១ ខែ មុនពេលសម្រាលកូន។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ការតម្រូវឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពចំនួន ១ ខែ មុនពេលសម្រាលកូនធ្វើឱ្យពួកគាត់បានឈប់សម្រាកបានតែរយៈពេលជាង ១ ខែ ក្រោយពេលសម្រាលកូនរួច។ ភាគីនិយោជកបានបញ្ជាក់ថា ការដែលកម្មករនិយោជិតជាស្ត្រីឈប់សម្រាកលំហែមាតុភាពកៀកពេលសម្រាលកូន គឺនាំឱ្យមានហានិភ័យ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ១៨២ នៃច្បាប់ស្តីពីការងារផ្តល់សិទ្ធិដល់កម្មករនិយោជិតមានផ្ទៃពោះចំនួន ៩០ ថ្ងៃ ដើម្បីសម្រាលកូន ហើយការតម្រូវរបស់និយោជកឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពចំនួន ១ ខែ មុនពេលសម្រាលកូននេះ គឺធ្វើឱ្យកម្មករនិយោជិតសាមីនៅសល់ថេរវេលាសម្រាកខ្លី ក្រោយសម្រាលកូនរួច ហើយត្រូវត្រឡប់ចូលធ្វើការវិញ ឆាប់ជាងក្នុងស្ថានភាពនៅសរសៃខ្ចី។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនអាចកំណត់ជាគោលការណ៍លើការឈប់សម្រាកលំហែមាតុភាពចំនួន ១ ខែ មុនពេលសម្រាលកូន សម្រាប់កម្មករនិយោជិតដែលមានផ្ទៃពោះទាំងអស់ដូចគ្នាទេ ដោយសារសុខភាពរបស់ពួកគាត់ម្នាក់ៗខុសគ្នា ហើយមានតែសាមីខ្លួនគាត់ផ្ទាល់ដែលបានពិគ្រោះយោបល់ និងពិនិត្យសុខភាពជាមួយគ្រូពេទ្យទើបអាចដឹងអំពីសុខភាពផ្ទាល់ខ្លួនរបស់ពួកគាត់ថា ពេលណាគាត់គួរតែដាក់ច្បាប់សុំនិយោជកដើម្បីចាប់ផ្តើមឈប់សម្រាកលំហែមាតុភាព។ លើសពីនេះទៀត ពេលវេលាក្រោយការសម្រាលកូន គឺជាពេលសំខាន់សម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រីសម្រាកឱ្យបានគ្រប់គ្រាន់ និងមានពេលសម្រាប់មើលថែកូន។

ប្រការ ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណើរ ជួយបង្ហើយសំណើ*

THE ARBITRATION COUNCIL

*ខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ៖*

*ក....*

*ខ. ...*

*គ. ...*

*ឃ. បញ្ជាឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តទាំងឡាយណាដែលមិនស្របច្បាប់...*

*...”។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជកទាក់ទងនឹងការតម្រូវឱ្យកម្មករនិយោជិតមានផ្ទៃពោះសម្រាកលំហែមាតុភាពចំនួន ១ ខែ មុនពេលសម្រាលកូន គឺមិនត្រឹមត្រូវទេ។ ហេតុនេះ យោងតាមប្រការ ៣៤ នៃប្រកាស ០៩៩ ខាងលើ និយោជកត្រូវបញ្ឈប់ការអនុវត្តនេះ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ៖

- បង្គាប់ឱ្យនិយោជកបញ្ឈប់ការអនុវត្តឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពចំនួន ១ ខែ មុនពេលសម្រាលកូន។
- បង្គាប់ឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពទៅតាមការស្នើសុំជាក់ស្តែងរបស់កម្មការនីជាសាមីខ្លួន ដោយខ្លួនឯង។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ៖**

- បង្គាប់ឱ្យនិយោជកអនុវត្តតាមចំណុច ៤.២.២.៦ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ដោយត្រូវទទួលស្គាល់រាល់លិខិតបញ្ជាក់ដែលចេញដោយគ្រូពេទ្យ *នៃមន្ទីរពេទ្យស្របច្បាប់ (បានចុះបញ្ជី) ដោយមានឈ្មោះ ឬហត្ថលេខារបស់គ្រូពេទ្យ* ។

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលសម្រាលកូនរួចនូវពេលចំនួន ១ ម៉ោង នៅចុងម៉ោងការងារ (ម៉ោង ៣ ៖ ០០ ដល់ ៤ ៖ ០០ រសៀល) ដើម្បីបំបៅកូន។
- បង្គាប់ឱ្យនិយោជកអនុញ្ញាតពេលចំនួន ១ ម៉ោង ក្នុងម៉ោងការងារ សម្រាប់កម្មករនិយោជិតជាស្ត្រីដែលបំបៅកូនឱ្យស្របតាមមាត្រា ១៨៤ នៃច្បាប់ស្តីពីការងារ។

THE ARBITRATION COUNCIL

**ចំណុចវិវាទទី ៣ ៖**

- បង្គាប់ឱ្យនិយោជកបញ្ឈប់ការអនុវត្តឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាព ចំនួន ១ ខែ មុនពេលសម្រាលកូន ។
- បង្គាប់ឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតមានផ្ទៃពោះឈប់សម្រាកលំហែមាតុភាពទៅតាមការស្នើសុំជាក់ស្តែងរបស់កម្មការនីជាសាមីខ្លួនដោយខ្លួនឯង ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **តាំង ទ្រី**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL